01327289

E418/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 13 / 09 / 2016
ម៉ោង (Time/Heure): 14:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម យ៉ា សុខន ជ.ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូរ ឧត្តរា
ចៅក្រម Claudia FENZ
ចៅក្រម ធូ មណី

កាលបរិច្ឆេទ: ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

---

**សេចក្តីសម្រេចលើសំណើសុំការអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GIRAUD

**អ្នកដាក់ពាក្យសុំ**
Annie BUNTING
Jean ALLAIN
Izevbuwa IKHIMIUKOR
Luke MOFFETT
Joel QUIRK

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៦ ក្រុមបញ្ញវន្ត និង អ្នកស្រាវជ្រាវផ្នែកច្បាប់អន្តរជាតិមួយក្រុម ("អ្នកដាក់ពាក្យសុំ") បានសុំការអនុញ្ញាតដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*ស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំមកកាន់អង្គជំនុំជម្រះសាលាដំបូង ("សំណើសុំ")[1]។ នៅថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៦ មេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន បានដាក់ចម្លើយតបរៀងៗខ្លួនទៅនឹងសំណើសុំនេះ[2]។

## ២. សារណា

### ២.១ សំណើរបស់អ្នកដាក់ពាក្យសុំ

២. អ្នកដាក់ពាក្យសុំអះអាងថា ពួកគាត់គឺជាអ្នកស្រាវជ្រាវអន្តរជាតិឯករាជ្យ ដែលនឹងផ្តល់យោបល់ឥតលម្អៀងជូនអង្គជំនុំជម្រះ។ ពួកគាត់អះអាងថា ពួកគាត់អាចផ្តល់ជូនអង្គជំនុំជម្រះនូវការវិភាគ និង ព័ត៌មានពិសេសដែលពុំត្រូវបានបោះពុម្ពផ្សាយ ដោយផ្អែកលើបទពិសោធន៍ចំនួន ៨ ឆ្នាំ នៅក្នុងការអភិវឌ្ឍច្បាប់ស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងទម្រង់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រមទាំងបទពិសោធន៍បម្រើការងារជាមួយក្រុមនានានៅក្នុងបណ្តាប្រទេសមួយចំនួន ដែលអាពាហ៍ពិពាហ៍ដោយបង្ខំបានកើតមានឡើងនៅក្នុងជម្លោះប្រដាប់អាវុធ។ ពួកគាត់បានអះអាងថា សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ដែលពួកគាត់បានស្នើឡើងនេះនឹងបន្ថែមតម្លៃដល់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ តាមរយៈការវិភាគបែបប្រៀបធៀប[3]។ អ្នកដាក់ពាក្យសុំក៏អះអាងផងដែរថា ការដាក់សារណានេះគឺសមស្របនៅក្នុងកិច្ចដំណើរការនីតិវិធីដំណាក់កាលនេះ ពីព្រោះអង្គជំនុំជម្រះជិតចាប់ផ្តើមសវនាការលើប្រធានបទនេះហើយ ហើយថា វានឹងមិន

---

[1] សំណើសុំការអនុញ្ញាតដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*ស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ ឯកសារ E418 ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៦ ("សំណើសុំ")។

[2] ចម្លើយតបរបស់ នួន ជា ទៅនឹងសំណើសុំដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ ឯកសារ E418/1 ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៦ ("ចម្លើយតបរបស់ នួន ជា")។ ការជំទាស់របស់មេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងការទទួលយកសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ *(ឯកសារ E418)* ឯកសារ E418/2 ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៦ ("ចម្លើយតបរបស់ ខៀវ សំផន")។

[3] សំណើសុំ កថាខណ្ឌ ៦-៧, ១០។

មានការពន្យារពេលសំណុំរឿង ០០២/០២ ឡើយ ពីព្រោះសារណាពេញលេញបានត្រៀមដាក់ជូនអង្គជំនុំជម្រះរួចជាស្រេចហើយ ប្រសិនបើអង្គជំនុំជម្រះអនុញ្ញាត[4]។

៣. អ្នកដាក់ពាក្យសុំស្នើសុំការអនុញ្ញាតដាក់សារណាក្នុងនាមជា*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*ដែលនឹង៖

១) ធ្វើការវិភាគមួយអំពីការកំណត់បទចោទអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងទម្រង់ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀត។ និង

២) បង្ហាញភាពខុសគ្នារវាងអាពាហ៍ពិពាហ៍ដោយបង្ខំ និង អាពាហ៍ពិពាហ៍ដោយការរៀបចំ។

## ២.២ __ចម្លើយតបរបស់ នួន ជា__

៤. មេធាវីការពារក្តី នួន ជា អះអាងថា សំណើសុំនេះគឺលឿនពេក ពីព្រោះភាគីនៅក្នុងសំណុំរឿង ០០២ ពុំទាន់មានឱកាសដាក់សារណារបស់ខ្លួនស្តីពីបញ្ហាទាក់ទិននឹងអាពាហ៍ពិពាហ៍ដោយបង្ខំនៅឡើយទេ។ ដោយផ្អែកលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល មេធាវីការពារក្តីអះអាងថា តួនាទីចម្បងរបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*លើបញ្ហាច្បាប់គឺ "ដើម្បីបន្ថែមឱ្យបានគ្រប់គ្រាន់ទៅលើអំណះអំណាងដែលបានទទួលរួចហើយពីភាគីនៃរឿងក្តីនេះ[5]។ មេធាវីការពារក្តីអះអាងថា អ្នកដាក់ពាក្យសុំខកខានមិនបានបង្ហាញថាតើតម្លៃបន្ថែមអ្វីទៅដែលសារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* នឹងបំពេញបន្ថែមទៅលើអំណះអំណាងជាសក្តានុពលរបស់ភាគីនៅក្នុងសំណុំរឿង ០០២ នោះ។ ជាពិសេស មេធាវីការពារក្តី នួន ជា អះអាងថា បទពិសោធន៍អ្នកដាក់ពាក្យសុំដែលធ្វើការជាមួយអ្នកនៅរស់រានមានជីវិតពីអាពាហ៍ពិពាហ៍ដោយបង្ខំពីប្រទេសដទៃទៀតគឺមិនពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ទេ ហើយថា ការវិភាគថាតើហេតុអ្វីបានជាអាពាហ៍-ពិពាហ៍ដោយបង្ខំគួរត្រូវបានកំណត់ជាបទល្មើសនោះ នឹងមិនរួមចំណែកដល់ការកាត់សេចក្តីដ៏ត្រឹម

---

[4] សំណើសុំ កថាខណ្ឌ ៨, ១០។

[5] ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ៨ ដែលដកស្រង់ចេញពីសេចក្តីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬ សុំដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីនៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ (អ.ជ.ត.ក) ឯកសារ F20/1 ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៥ កថាខណ្ឌ ៨ ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក")។

ត្រូវនៃសំណុំរឿងនេះទេ ពីព្រោះការអនុវត្តប្រតិសកម្មនៃច្បាប់ដែលបង្កើតឡើងនាពេលក្រោយមកទៀតនោះ គឺផ្ទុយទៅនឹងគោលការណ៍នីត្យានុកូលភាពជាសារវ័ន្ត[6]។

៥. មេធាវីការពារក្តី នួន ជា អះអាងថា សំណើសុំនេះគឺពុំមានភាពសត្យានុម័ត និង វិជ្ជាជីវៈឡើយ ដោយសារនៅក្នុងសំណើសុំនេះមានការដកស្រង់ខុសនូវសេចក្តីសម្រេច និង ការសរសេរឈ្មោះសាស្ត្រាចារ្យម្នាក់ខុសនៅលើទំព័រមុខ ហើយថា ជំនាញរបស់អ្នកដាក់ពាក្យសុំនីមួយៗនោះ មានលក្ខណៈស្រពិចស្រពិល[7]។ លើសពីនេះទៀត មានការអះអាងថា ការទទួលយកសារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* នឹងតម្រូវយ៉ាងជាក់ស្តែងឱ្យមេធាវីការពារក្តីឆ្លើយតបទៅនឹងភាគីទីបី ដោយសារតែសារណានេះផ្តល់ផលប្រយោជន៍យ៉ាងច្បាស់ក្រឡែតទៅឱ្យសហព្រះរាជអាជ្ញា និង ដើមបណ្តឹងរដ្ឋប្បវេណី។ ជាចុងក្រោយ មេធាវីការពារក្តី នួន ជា អះអាងថា ការទទួលយកសារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*នឹងពន្យារពេលកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០២ ពីព្រោះភាគីមានសិទ្ធិទទួលបានពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងសារណានេះ បន្ទាប់ពីការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល[8]។

## ២.៣ __ចម្លើយតបរបស់ ខៀវ សំផន__

៦. មេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងសំណើសុំនេះ[9]។ មេធាវីការពារក្តីអះអាងថា សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* មិនមានភាពជាប់ទាក់ទិនឡើយ ពីព្រោះសារណានេះមិនបានលើកឡើងអំពីស្ថានភាពច្បាប់នៅក្នុងពេលវេលាពាក់ព័ន្ធទេ ហើយអ្នកដាក់ពាក្យសុំពុំមានបទពិសោធន៍ពាក់ព័ន្ធ ឬចំណេះដឹងអំពីប្រទេសកម្ពុជាឡើយ ជាពិសេសទាក់ទិនទៅនឹងអំឡុងពេលវេលាដែលពាក់ព័ន្ធនឹង អ.វ.ត.ក[10]។ មេធាវីការពារក្តីអះអាងថា សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ព្យាយាមគាំទ្រចំពោះការទទួលស្គាល់អាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិជាទូទៅ[11]។ ចុងក្រោយ មេធាវីការពារក្តីអះអាងថា ការដាក់សារណា*របស់អ្នកដែល*

---

[6] ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ៩-១៣។

[7] ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ១៤-១៧។

[8] ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ១៨-១៩។

[9] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ២, ១២។

[10] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៧-៨។

[11] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៩។

*មិនមែនជាភាគីនៃរឿងក្តី* នៅដំណាក់កាលនេះគឺធ្វើឡើងឆាប់ពេក ពីព្រោះសារណានេះគ្រាន់តែមានខ្លឹមសារបន្ថែមទៅលើទឡ្ហីករណ៍នានារបស់ភាគីនៅក្នុងសំណុំរឿង០០២/០២ ប៉ុណ្ណោះ ដែលទឡ្ហីករណ៍ទាំងនោះនឹងដាក់ជូន តែនៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ភាគីរៀងៗខ្លួនប៉ុណ្ណោះ[12]។

## ៣. ច្បាប់ជាធរមាន

៧. វិធាន ៣៣ នៃវិធានផ្ទៃក្នុងចែងថា "បើយល់ថាចាំបាច់ដើម្បីវិនិច្ឆ័យទោសឲ្យបានត្រឹមត្រូវ អង្គជំនុំជម្រះអាចអញ្ជើញ ឬផ្តល់ឱកាសឲ្យអង្គការ ឬបុគ្គលណាមួយដាក់ជូននូវសារណាជាលាយលក្ខណ៍អក្សរ ពាក់ព័ន្ធនឹងបញ្ហាណាមួយក៏បាន ក្នុងនាមជាអ្នកឯកទេសអមតុលាការ"។ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ជាធម្មតាគឺជាអ្នកប្រឹក្សាឯករាជ្យ និង ឥតលម្អៀងចំពោះតុលាការដែលមានតួនាទីគ្រាន់តែផ្តល់យោបល់ ប៉ុន្តែមិនត្រូវប្រកាន់ជំហរណាមួយនោះទេ[13]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ច្បាស់ថា សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ត្រូវកម្រិតត្រឹមតែបញ្ហាផ្នែកច្បាប់ និង មិនអាចដាក់បញ្ចូលភស្តុតាងផ្នែកអង្គហេតុទាក់ទិននឹងធាតុផ្សំនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ឡើយ[14]។ ការពិចារណាជាបឋមនៅក្នុងការអនុញ្ញាតឲ្យដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* គឺថាតើតុលាការនឹងទទួលបានផលប្រយោជន៍ដែរ ឬ ទេ នៅក្នុងការវិនិច្ឆ័យរឿងក្តីឲ្យបានត្រឹមត្រូវ[15]។ វិធាន ៣៣ នៃវិធានផ្ទៃក្នុងចែងបន្ថែមទៀតថា នៅក្នុងករណី

---

[12] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ១០។

[13] សេចក្តីសម្រេចលើសំណើសុំការអនុញ្ញាតដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ឯកសារ E306/3/1 កថាខណ្ឌ ៥។ សូមមើល ផងដែរ សេចក្តីសម្រេចលើសំណើសុំអនុញ្ញាតដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ឬ ចូលរួមធ្វើអន្តរាគមន៍លើភាពអាចទទួលយកបាន និង ការប្រើប្រាស់ភស្តុតាងដែលទទួលបានតាមរយៈទារុណកម្ម ឯកសារ E350/7 ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៥ កថាខណ្ឌ ៥។ ពាក្យសុំរបស់លោក អៀង សារី សុំដកគុណវុឌ្ឍិសាស្ត្រាចារ្យ កាសេស៊ី (Cassese) និង សមាជិកមួយចំនួននៃក្រុមប្រឹក្សានិពន្ធ និង គណៈកម្មាធិការនិពន្ធ និង ទិនានុប្បវត្តិតុលាការព្រហ្មទណ្ឌអន្តរជាតិ ពីការដាក់សារណាជាលាយលក្ខណ៍អក្សរ*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ស្តីពីបញ្ហាសហឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះករណី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ឯកសារ D99/3/18 ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ១១។

[14] ព័ត៌មានស្តីអំពីការដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ជូនទៅអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក កថាខណ្ឌ ៥(ខ)។

[15] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ១១។

ដែលមានការអនុញ្ញាតឱ្យដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* អង្គជំនុំជម្រះត្រូវកំណត់ពេលវេលាឱ្យដាក់សារណាបែបនេះ ហើយភាគីដទៃទៀតត្រូវមានឱកាសដើម្បីឆ្លើយតប។

## ៤. **សំអាងហេតុ**

៨. អង្គជំនុំជម្រះកត់សម្គាល់ថា អនុលោមតាមវិធាន ៣៣ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះក្នុងមានឆន្ទានុសិទ្ធិក្នុងការវាយតម្លៃថាតើ សារណាដែលស្នើឡើងនោះចាំបាច់សម្រាប់ការវិនិច្ឆ័យរឿងក្ដីឱ្យបានត្រឹមត្រូវដែរ ឬ ទេ។ ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ ត្រូវបានចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[16]។ បញ្ហាដែលបានស្នើសុំធ្វើការពន្យល់ រួមមាន (១) ការវិវត្តន៍ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងទម្រង់ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង (២) ភាពខុសគ្នាផ្នែកអង្គហេតុ និង អង្គច្បាប់រវាងអាពាហ៍ពិពាហ៍ដោយការរៀបចំនៅក្នុងអំឡុងពេលមានសន្តិភាព និង អាពាហ៍ពិពាហ៍ដោយបង្ខំក្រោមរបបជិះជាន់ ឬ ក្នុងពេលមានជម្លោះប្រដាប់អាវុធ គឺទាក់ទិនដោយផ្ទាល់ទៅនឹងបទចោទទាំងនេះ[17]។ ហេតុដូច្នេះ សារណានេះអាចជាជំនួយនៅក្នុងការវាយតម្លៃអំពីច្បាប់ដែលអាចយកមកអនុវត្តបានចំពោះបទចោទទាំងនេះនៅក្នុងដីកាដំណោះស្រាយ។ ទោះបីជាអ្នកដាក់ពាក្យសុំអាចពុំមានបទពិសោធន៍នៅក្នុងបរិបទកម្ពុជាក៏ដោយ ក៏ចំណុចនេះមិនរារាំងដល់ការដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* ស្ដីអំពីបញ្ហាផ្នែកច្បាប់សុទ្ធសាធនោះឡើយ។

៩. ចម្លើយតបរបស់ក្រុមមេធាវីការពារក្ដីលើកឡើងនូវក្ដីកង្វល់អំពីភាពជាប់ពាក់ព័ន្ធនៃសារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* ដែលបានស្នើឡើងនេះ ដោយសារតែសារណានេះមិនបានលើកឡើងអំពីស្ថានភាពច្បាប់នៅក្នុងពេលវេលាពាក់ព័ន្ធ ឬ ដោយសារតែសារណានេះមានគោលបំណងគាំទ្រចំពោះការវិវត្តជាក់លាក់នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលអាចរំលោភទៅលើគោលការណ៍នីត្យានុកូលភាព។ ដើម្បីបង្ការកុំឱ្យមានការរំលោភបែបនេះ អំណះអំណាងនៅក្នុងសារណាដែលបានស្នើឡើងនេះ នឹងត្រូវកម្រិតត្រឹមការវិវត្ត និង ស្ថានភាពច្បាប់ដែលពាក់ព័ន្ធឆ្នាំ

[16] ដីកាដំណោះស្រាយ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស ឯកសារ D427 ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៤៤២-១៤៤៧។ សូមមើល ផងដែរ ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ មាត្រា ៥។

[17] សំណើសុំ កថាខណ្ឌ ១៣, ១៧។

១៩៧៥ ដល់ឆ្នាំ ១៩៧៩ ប៉ុណ្ណោះ។ អំណះអំណាងទាំងនេះ នឹងទាក់ទិនយ៉ាងជាក់ច្បាស់ទៅនឹងរឿងក្ដីបច្ចុប្បន្ននេះ។

១០. អង្គជំនុំជម្រះក៏កត់សម្គាល់ផងដែរថា មេធាវីការពារក្ដី នួន ជា ជំទាស់ទៅនឹងភាពជាប់ទាក់ទិននៃការពិភាក្សាអំពីសក្ខីកម្មអង្គហេតុ និងបទពិសោធន៍របស់អ្នកនៅរស់រានមានជីវិតពីអាពាហ៍ពិពាហ៍ដោយបង្ខំពីបណ្ដាប្រទេសដទៃទៀត រួមទាំង ប្រទេសសៀរ៉ាឡេអូន[18]។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងបរិបទពាក់ព័ន្ធ មេធាវីការពារក្ដី នួន ជា អះអាងថា មេធាវីការពារក្ដីចង់ពិភាក្សាអំពីស្ថានភាពនៅក្នុងប្រទេសសៀរ៉ាឡេអូន ជាមួយនឹងអ្នកជំនាញដែលនឹងត្រូវផ្ដល់សក្ខីកម្មក្នុងពេលឆាប់ៗខាងមុខនេះ ពីព្រោះតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("តុលាការ SCSL") គឺជាតុលាការមុនគេ និង ជាតុលាការតែមួយគត់ ដែលមានយុត្តាធិការលើឧក្រិដ្ឋកម្មអន្តរជាតិក្នុងការសម្រេចទៅលើបញ្ហាអាពាហ៍ពិពាហ៍ដោយបង្ខំ" ហើយជម្លោះនៅក្នុងប្រទេសសៀរ៉ាឡេអូន មានយោងនៅក្នុងរបាយការណ៍របស់អ្នកជំនាញរូបនោះ[19]។ អង្គជំនុំជម្រះទទួលយកទឡ្ហីករណ៍ចុង-ក្រោយនេះ ហើយអង្គជំនុំជម្រះយល់ឃើញថា វាអាចជាការសមស្របសម្រាប់*អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* យោងទៅលើជម្លោះនៅប្រទេសសៀរ៉ាឡេអូន និង យុត្តិសាស្ត្ររបស់តុលាការ SCSL។

១១. លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្ដីពុំបានបង្ហាញឱ្យឃើញថា អ្នកដាក់ពាក្យសុំពុំមានភាពសក្សានុម័ត និង វិជ្ជាជីវៈនោះឡើយ។ អ្នកដាក់ពាក្យសុំ គឺពិតជាស្ថិតនៅក្នុងវិសាលភាពនៃ*អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* ដូចដែលបានកំណត់ដោយ អ.ជ.ត.ក ពោលគឺ ពុំទទួលបានផលប្រយោជន៍នៅក្នុងលទ្ធផលនៃកិច្ចដំណើរការនីតិវិធី[20]។ លើសពីនេះទៀត ភាគីទាំង

---

[18] ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ១២។

[19] សូមមើល សំណើអនុលោមតាមវិធាន ៨៧(៤) និង វិធាន ៩៣ នៃវិធានផ្ទៃក្នុងរបស់ នួន ជា ពាក់ព័ន្ធនឹងអ្នកជំនាញដែលមានឈ្មោះហៅក្រៅ 2-TCE-82 (NAKAGAWA Kasumi) ឯកសារ E431/3 ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ កថាខណ្ឌ ១៦។

[20] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ១១។ សូមមើល ផងដែរ រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Laurent Gbagbo* អង្គបុរេជំនុំ-ជម្រះ III នៃតុលាការ ICC (សំណុំរឿង ICC-02/11-01/11-50) សេចក្ដីសម្រេចលើពាក្យសុំរបស់ Redress Trust នូវការអនុញ្ញាតដើម្បីដាក់សេចក្ដីសង្កេតជូនអង្គបុរេជំនុំជម្រះ III នៃតុលាការ ICC អនុលោមតាមវិធាន ១០៣ នៃវិធានស្ដីពីនីតិវិធី និងភស្តុតាង ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០១២។ សូមមើល ផងដែរ រឿងក្ដីរដ្ឋអាជ្ញា ទល់នឹង *Jean-Pierre Bemba Gombo* អង្គបុរេ-ជំនុំជម្រះ II នៃតុលាការ ICC (សំណុំរឿង ICC-01/05-01/08-401) សេចក្ដីសម្រេចលើសំណើសុំអនុញ្ញាតដាក់សេចក្ដីសង្កេត*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* អនុលោមតាម ១០៣ នៃវិធានស្ដីពីនីតិវិធី និងភស្តុតាង ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៩។ សេចក្ដីសម្រេចលើសំណើសុំអនុញ្ញាតដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី* ឯកសារ E306/3/1 ថ្ងៃទី ០៤ ខែ

អស់នឹងមានឱកាសឆ្លើយតប និង កំណត់នូវកំហុសសំខាន់ៗ ឬ ការលើកឡើងមិនត្រឹមត្រូវ ប្រសិនបើមាននៅក្នុងសារណាដែលបានដាក់នោះ[21]។ អង្គជំនុំជម្រះរម្លឹកថា អង្គជំនុំជម្រះមិនជាប់កាតព្វកិច្ចត្រូវយល់ស្របតាមទឡ្ហីករណ៍នានាដែលមាននៅក្នុងសារណារបស់អ្នកដាក់ពាក្យសុំនោះឡើយ។

១២. អង្គជំនុំជម្រះកត់សម្គាល់ថា វិធាន ៣៣ នៃវិធានផ្ទៃក្នុង ចែងថា សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* អាចដាក់<u>នៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី</u> ប្រសិនបើចាំបាច់ដើម្បីវិនិច្ឆ័យរឿងក្តីបច្ចុប្បន្ននេះឱ្យបានត្រឹមត្រូវ[22]។ ប្រសិនបើរង់ចាំរហូតដល់ភាគីទាំងអស់ដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ខ្លួនជាមុនសិនទើបសម្រេចថាតើត្រូវទទួលយក ឬ មិនទទួលយកសារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* នោះ វាអាចកាន់តែពន្យារពេលកិច្ចដំណើរការនីតិវិធីថែមទៀត។ ផ្ទុយទៅវិញ ការទទួលយកសារណានៅពេលនេះនឹងផ្តល់ឱកាសឱ្យភាគីធ្វើការឆ្លើយតបទៅនឹងការស្រាវជ្រាវ ឬ អំណះអំណាងទាំងឡាយដែលបានលើកឡើងដោយអ្នកដាក់ពាក្យសុំ។ អង្គជំនុំជម្រះយល់ឃើញថា ការកំណត់ពេលវេលានេះនាំឱ្យកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅតាមលំដាប់លំដោយកាន់តែត្រឹមត្រូវ និង មានប្រសិទ្ធភាពថែមទៀត[23]។

១៣. អង្គជំនុំជម្រះកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "តួនាទីចម្បងរបស់*អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*នៅក្នុងបញ្ហាច្បាប់ព្រហ្មទណ្ឌអន្តរជាតិគឺជាការជួយដល់តុលាការនៅក្នុងការសម្រេចលើរឿងក្តី [...] ដោយមានខ្លឹមសារជួយ<u>បន្ថែមឱ្យបានគ្រប់គ្រាន់ទៅលើទឡ្ហីករណ៍</u>

---

មិថុនា ឆ្នាំ ២០១៤ កថាខណ្ឌ ៥។ *សូមមើល ផងដែរ* ពាក្យសុំរបស់លោក អៀង សារី សុំដកគុណវុឌ្ឍិសាស្ត្រាចារ្យ កាសេស៊ី (Cassese) និង សមាជិកមួយចំនួននៃក្រុមប្រឹក្សានិពន្ធ និង គណៈកម្មាធិការនិពន្ធ និង ទិនានុប្បវត្តិតុលាការព្រហ្មទណ្ឌអន្តរជាតិ ពីការដាក់សារណាជាលាយលក្ខណ៍អក្សរ*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ស្តីពីបញ្ហាសហឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះករណី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ឯកសារ D99/3/18 ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ១១។ សេចក្តីសម្រេចលើសំណើសុំអនុញ្ញាតដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ឬ ចូលរួមធ្វើអន្តរាគមន៍លើភាពអាចទទួលយកបាន និង ការប្រើប្រាស់ភស្តុតាងដែលទទួលបានតាមរយៈទារុណកម្ម ឯកសារ E350/7 ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៥ កថាខណ្ឌ ៥។

[21] សូមមើល ចម្លើយតបរបស់ នួន ជា កថាខណ្ឌ ១៤-១៦។ ព័ត៌មានស្តីអំពីការដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ជូនទៅអង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក កថាខណ្ឌ ៤។

[22] វិធាន ៣៣ នៃវិធានផ្ទៃក្នុង (សេចក្តីបញ្ជាក់បន្ថែម)។

[23] វិធាន ២១ នៃវិធានផ្ទៃក្នុង។

នានាដែលបានទទួលរួចហើយពីភាគីនៃរឿងក្តី"[24]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សេចក្តីសង្កេតរបស់អង្គជំនុំជម្រះតុលាការកំពូល គឺទាក់ទិនទៅនឹងខ្លឹមសារជាជាងការកំណត់ពេលវេលានៃសារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*។ បញ្ហាដែលបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនោះ គឺបញ្ហាថាតើ ត្រូវទទួលយក ឬ មិនទទួលយកព័ត៌មានពិស្តារបន្ថែមទៀតអំពីបញ្ហាមួយ (សហឧក្រិដ្ឋកម្មរួម) ដែលត្រូវបានជំទាស់តវ៉ាយ៉ាងច្រើនរួចហើយនៅក្នុងដំណាក់កាលមុនជំនុំជម្រះ និង ដំណាក់កាលជំនុំជម្រះក្តី។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សារណាដែលបានស្នើឡើងនោះគឺជាន់គ្នាជាមួយនឹងអ្វីដែលមានរួចហើយនៅចំពោះមុខអង្គជំនុំជម្រះ ដូច្នេះហើយវាអាចនាំឱ្យមានការពន្យារពេលឥតប្រយោជន៍[25]។ ផ្ទុយទៅវិញ មានសារណាតិចតួចមែនទែននៅក្នុងសំណុំរឿងនេះ ពាក់ព័ន្ធនឹងអត្ថិភាព និង ប្រភេទនៃអំពើអមនុស្សធម៌ផ្សេងៗទៀតនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ ហេតុដូច្នេះ សារណាបន្ថែមទៀតអំពីប្រធានបទនេះ នឹងផ្តល់ផលប្រយោជន៍ដល់អង្គជំនុំជម្រះ។

១៤. ទាក់ទិននឹងការលើកឡើងរបស់មេធាវីការពារក្តី នួន ជា និង មេធាវីការពារក្តី ខៀវ សំផន ស្តីអំពីបញ្ហាសមភាពនៃមធ្យោបាយក្នុងការតទល់ក្តី អង្គជំនុំជម្រះកត់សម្គាល់ថា តុលាការព្រហ្មទណ្ឌអន្តរជាតិបានទទួលយកសារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* អំពីបញ្ហាច្បាប់ ប្រសិនបើសារណានោះត្រូវបានពិចារណាថាទាក់ទិនទៅនឹងកិច្ចដំណើរការនីតិវិធី និង រួមចំណែកនៅក្នុងការសម្រេចរឿងក្តីនោះឱ្យបានត្រឹមត្រូវ[26]។ ការបញ្ជាក់បង្ហាញអំពីស្ថានភាពច្បាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម

---

[24] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ១៣ (សេចក្តីបញ្ជាក់បន្ថែម)។

[25] សេចក្តីសម្រេចរបស់ អ.ជ.ត.ក កថាខណ្ឌ ១៣-១៤។

[26] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Laurent Gbagbo* អង្គបុរេជំនុំជម្រះ III នៃតុលាការ ICC (សំណុំរឿង ICC-02/11-01/11-50) សេចក្តីសម្រេចលើពាក្យសុំរបស់ Redress Trust នូវការអនុញ្ញាតដើម្បីដាក់សេចក្តីសង្កេតជូនអង្គបុរេជំនុំជម្រះ III នៃតុលាការ ICC អនុលោមតាមវិធាន ១០៣ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ៧។រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Laurent Gbagbo* អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC (សំណុំរឿង ICC-02/11-01/11-516) សេចក្តីសម្រេចលើសំណើសុំអនុញ្ញាតដាក់សេចក្តីសង្កេត*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* អនុលោមតាម ១០៣ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ១០។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Sainovic* និង អ្នកផ្សេងទៀត អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (សំណុំរឿង IT-05-87-A) សេចក្តីសម្រេចលើពាក្យសុំរបស់ David J. Scheffer ដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១០។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Jean-Pierre Bemba Gombo* អង្គបុរេជំនុំជម្រះនៃតុលាការ ICC (សំណុំរឿង ICC-01/05-01/08-451) សេចក្តីសម្រេចលើសំណើសុំអនុញ្ញាតដាក់ សេចក្តីសង្កេត*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* អនុលោមតាម ១០៣ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩ កថាខណ្ឌ ១២។ រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Jean-Pierre Bemba Gombo* អង្គបុរេជំនុំជម្រះ II នៃ

ប្រឆាំងនឹងមនុស្សជាតិមិនមែនជាបញ្ហារបស់ក្រុមណាមួយ ដែលអាចបង្កើតឱ្យមាននូវអតុល្យភាពនៃមធ្យោបាយនោះឡើយ។ តាមពិត ការស្រាវជ្រាវដែលមាននៅក្នុងសារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ដែលបានស្នើឡើងនោះអាចជាជំនួយទៅដល់គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្តីនេះ។

១៥. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា បញ្ហាដែលអ្នកដាក់ពាក្យសុំលើកឡើងនៅក្នុងសារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* គឺចាំបាច់សម្រាប់ការវិនិច្ឆ័យឱ្យបានត្រឹមត្រូវទៅលើសំណុំរឿង ០០២/០២។

**តាមសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

**អនុញ្ញាត** ឱ្យអ្នកដាក់ពាក្យសុំដាក់សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*។

**រម្លឹក** ដល់អ្នកដាក់ពាក្យសុំថា សារណា*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ត្រូវលើកឡើងតែអំពីស្ថានភាពច្បាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈអាពាហ៍ពិពាហ៍ដោយបង្ខំ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ប៉ុណ្ណោះ។

**បង្គាប់** ឱ្យអ្នកដាក់ពាក្យសុំដាក់សារណាមិនឱ្យហួសថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៦ ដែលមានចំនួនទំព័រមិនឱ្យលើសពី ២០ ទំព័រ ជាភាសាអង់គ្លេស ឬ បារាំងឡើយ។ និង

**កត់សម្គាល់** ភាគីអាចឆ្លើយតបទៅនឹងសារណានេះនៅក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃដាក់សារណានេះ និង/ឬ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ពួកគេ។

ភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦

**ជ. ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE PREMIÈRE INSTANCE

**យ៉ា សុខន**

---

គុលាការ ICC (សំណុំរឿង ICC-01/05-01/08-401) សេចក្តីសម្រេចលើសំណើសុំអនុញ្ញាតដាក់សេចក្តីសង្កេត*របស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* អនុលោមតាម ១០៣ នៃវិធានស្តីពីនិតិវិធី និងភស្តុតាង ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៩ កថាខណ្ឌ ១២។